ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ៨៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាការអនុវត្តសិទ្ធិទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសជាបុរសឬជាស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរហើយមានបំណងទាមទារសញ្ជាតិខ្មែរ។

## ជំពូកទី២

## បែបបទនៃការទាមទារសញ្ជាតិខ្មែរ

**មាត្រា ៤.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលមានបំណងទាមទារសញ្ជាតិខ្មែរ ត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃ។

**មាត្រា ៥.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលទាមទារសញ្ជាតិខ្មែរ ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំនិងត្រូវបំពេញបែបបទដូចខាងក្រោម៖

- ពាក្យសុំទាមទារសញ្ជាតិខ្មែរចំនួន០២(ពីរ)ច្បាប់
- លិខិតបញ្ជាក់ឯកភាពរបស់សហព័ទ្ធជាពលរដ្ឋខ្មែរចំនួន០២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនមានស្នាមម្រាមដៃ ឈ្មោះ មានបិទរូបថតទំហំ ៤ស.ម.គុណ៦ស.ម.ចំនួន ០២(ពីរ)ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០(ដប់)សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- លិខិតបញ្ជាក់ទីលំនៅនិងលិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំឬចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន០១(មួយ)ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន០១ (មួយ) ច្បាប់ ដោយមានបញ្ជាក់ពីស្ថានទូតឬស្ថានតំណាងរបស់ខ្លួន
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន០២(ពីរ)ច្បាប់
- លិខិតឆ្លងដែនថតចម្លងរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន០២(ពីរ)ច្បាប់។

**មាត្រា ៦.-**

ការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីត្រូវបង់កម្រៃសេវារដ្ឋបាល។

កម្រៃសេវារដ្ឋបាលនៃការទាមទារសញ្ជាតិខ្មែរនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## នីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ

**មាត្រា ៧.-**

នីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំឯកសារសុំទាមទារសញ្ជាតិខ្មែរនិងនីតិវិធីប្តឹងជំទាស់របស់សហព័ទ្ធជាពលរដ្ឋខ្មែរចំពោះការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៩.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវប្រគល់ជូនសាមីខ្លួនបន្ទាប់ពីបានធ្វើសម្បថរួច ដោយក្រសួងមហាផ្ទៃ។

ខ្លឹមសារនៃសម្បថមានអត្ថន័យដូចតទៅ៖

« ខ្ញុំសូមសច្ចាជាឱឡារិកថាខ្ញុំមានភក្តីភាពនិងសេចក្តីស្នេហាចំពោះជាតិមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត »។

« ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការការពារឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត »។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ